- English
- Khmer

- អំពីសាលារាជធានី
- ទំនាក់ទំនងយើង
- វិចិត្រសាល
- ែផនទី
- អ៊ីមែល

ស្វែងរក...

- រាជធានីភ្នំពេញ
  - ទិដ្ឋភាពទូទៅ
  - ប្រវត្តិ
  - រតនភណ្ឌនៃភ្នំពេញ
  - ចំងាយពីភ្នំពេញទៅ បណ្ដាខេត្ត-ក្រុង
  - សេវាដឹកជញ្ជូនសាធារណៈរថយន្តក្រុង
  - អភិបាល រាជធានី
- សេវាសាធារណៈ
  - ការងារនីត្យានុកូលកម្ម
  - ការងាររដ្ឋបាល
  - ការងារវិនិេយាគ
  - វិស័យសុខាភិបាល
  - វិស័យទេសចរណ៍
  - វិស័យសាធារណការ និងដឹកជញ្ជូន
  - វិស័យវប្បធម៌ និងវិចិត្រសិល្បៈ
  - វិស័យព័ត៌មាន
  - វិស័យបរិស្ថាន

- ○ វិស័យឧស្សាហកម្ម និងសិប្បកម្ម
- ○ វិស័យរ៉ែ និងថាមពល
- ○ វិស័យពាណិជ្ជកម្ម
- ○ វិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ○ វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ○ វិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- ពាណិជ្ជកម្ម
  - អត្ថប្រយោជន៍
  - ច្បាប់និងបទបញ្ញា
  - របៀបស្នើសុំ
  - ឱកាសវិនិយោគ
  - គេហទំព័រពាណិជ្ជកម្មផ្សេងទៀត
- ភ្ញៀវ និងវិស័យទេសចរណ៍
  - មគ្គុទ្ទេសក៍ទេសចរណ៍
  - ព្រឹត្តិការណ៍និងសកម្មភាពផ្សេងៗ
  - ការរស់នៅ និង វប្បធម៌កម្ពុជា
  - មធ្យោបាយធ្វើដំណើរ
  - តំបន់ទេសចរណ៍
  - ផែនទីទេសចរណ៍
- ព័ត៌មាន និងសេចក្តីប្រកាស
  - សកម្មភាពគណៈអភិបាលរាជធានីភ្នំពេញ
  - ព័ត៌មានសាលារាជធានី
  - ពត៌មានតាមខណ្ឌ
  - ក្រុមប្រឹក្សារាជធានី
  - សេចក្តីប្រកាស
  - ការងាររៀបចំ និងគ្រប់គ្រងសហគមន៍ក្រីក្រ
- ការបោះពុម្ពផ្សាយ

123

# ព័ត៌មាន និងសេចក្ដីប្រកាស

- [សកម្មភាពគណៈអភិបាលរាជធានីភ្នំពេញ]
- [ព័ត៌មានសាលារាជធានី]
- [ព័ត៌មានតាមខណ្ឌ]
- [ក្រុមប្រឹក្សារាជធានី]
- [សេចក្ដីប្រកាស]
- [ការងាររៀបចំ និងគ្រប់គ្រងសហគមន៍ក្រីក្រ]

## លេខអាសន្ន




## ផែនទីកំណត់តម្លៃពន្ធអចលនទ្រព្យ




## ព្យាករណ៍អាកាសធាតុ

[beautiful-yahoo-weather]

## អត្រាប្តូរប្រាក់

1 USD = 4135 KHR
1 CNY = 579 KHR
1 JPY = 3856 KHR
1 THB = 129.8 KHR
[www.nbc.org.kh]

## តារាងទីផ្សារ

ប្រេងសាំង (រៀល/លីត្រ) = ៣,០០០

ប្រេងមាស៊ូត (រៀល/លីត្រ) = ២,៧០០

អង្ករ (រៀល/គីឡូក្រាម) = ២,៥០០

សាច់គោ (រៀល/គីឡូក្រាម) = ៤៤,០០០

សាច់ជ្រូក (រៀល/គីឡូក្រាម) = ៤០,០០០

អានបន្ត >>

ទូរស័ព្ទទាន់ហេតុការណ៍ ពីវីរុស កូវីដ១៩




ពត៌មានផ្សេងៗ

- ទាញយក ខ្មែរយូនីកូដ

ពត៌មានផ្សេងៗ

- ទាញយក ខ្មែរយូនីកូដ
- ពន្យល់កម្មវិធីជំនួយសង្គមជាសាច់ប្រាក់

ទំព័រដើម / ព័ត៌មាន និងសេចក្តីប្រកាស / សេចក្តីប្រកាស / សេចក្តីណែនាំ ស្តីពីការបន្តផ្អាកការលក់គ្រឿងស្រវ...

# សេចក្តីណែនាំ ស្តីពីការបន្តផ្អាកការលក់គ្រឿងស្រវឹងគ្រប់ប្រភេទ ក្នុងមូលដ្ឋានរាជធានីភ្នំពេញ

ថ្ងៃចេញផ្សាយ: Sunday, April 25, 2021, 8:05 PM

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលរាជធានីភ្នំពេញ**

លេខ: ០៦៤/២១ សណន

## សេចក្តីណែនាំ
## ស្តីពី
## ការបន្តផ្អាកការលក់គ្រឿងស្រវឹងគ្រប់ប្រភេទ ក្នុងមូលដ្ឋានរាជធានីភ្នំពេញ

កន្លងមក **រដ្ឋបាលរាជធានីភ្នំពេញ** បានដាក់ចេញនូវសេចក្តីណែនាំលេខ ០០៩/២១ សណន ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០២១ ស្តីពីការផ្អាកការលក់គ្រឿងស្រវឹងគ្រប់ប្រភេទ និងផ្អាកការទទួលអតិថិជនឱ្យចូលមកទទួលទានក្នុងភោជនីយដ្ឋាន អាហារដ្ឋាន តូបអាហារ ហាងកាហ្វេ ហាងភេសជ្ជៈ និងអាជីវកម្មដ្ឋានផ្នែកអាហារ-ភេសជ្ជៈគ្រប់ប្រភេទ ក្នុងនោះ ជាលទ្ធផលវិធានការនេះ បានរួមចំណែកយ៉ាងសំខាន់ ក្នុងការបង្ការ និងទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩ នៅរាជធានីភ្នំពេញ។

ចំពោះមុខ ដើម្បីឈានទៅគ្រប់គ្រងការឆ្លងរាលដាលជំងឺកូវីដ-១៩ ក្នុង **"ព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ ២០២១" រដ្ឋបាលរាជធានីភ្នំពេញ** សម្រេចបន្តផ្អាកការលក់គ្រឿងស្រវឹងគ្រប់ប្រភេទ តាមគោលការណ៍ណែនាំដូចខាងក្រោម៖

១. គ្រប់ទីផ្សារ ដេប៉ូចែកចាយភេសជ្ជៈ និងអាជីវកម្មដ្ឋានផ្នែកអាហារ-ភេសជ្ជៈគ្រប់ប្រភេទ ត្រូវបន្តផ្អាកជាបណ្តោះអាសន្ននូវការលក់គ្រឿងស្រវឹងគ្រប់ប្រភេទ ក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ រយៈពេល **២ (ពីរ) សប្តាហ៍បន្ថែមទៀត គិតចាប់ពីថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២១** ។

២. បុគ្គលទាំងឡាយណាដែលបន្តលក់ដូរ ចែកចាយ និងចរាចរណ៍គ្រឿងស្រវឹងគ្រប់ប្រភេទ ក្នុងអំឡុងពេលនៃការហាមឃាត់នេះ នឹងត្រូវទទួលទោស ដូចមានកំណត់ក្នុងច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

៣. រដ្ឋបាលខណ្ឌទាំង១៤ និងមន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ ត្រូវសហការចុះត្រួតពិនិត្យតាមបណ្តាគោលដៅទីផ្សារ ដេប៉ូចែកចាយភេសជ្ជៈ និងអាជីវកម្មដ្ឋានផ្នែកអាហារ-ភេសជ្ជៈគ្រប់ប្រភេទ ដើម្បីអនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំនេះ។ ក្នុងករណីរកឃើញថា គណៈគ្រប់គ្រងផ្សារ ម្ចាស់ដេប៉ូ ឬ ម្ចាស់អាជីវកម្មដ្ឋានណាមួយមិនព្រមសហការ ឬ មិនអនុវត្តតាមសេចក្តីណែនាំនេះ **ត្រូវអនុវត្តវិធានការរដ្ឋបាល និងវិធានការច្បាប់ដោយគ្មានការលើកលែងឡើយ។**

ទទួលបានសេចក្តីណែនាំនេះ នាយករដ្ឋបាលសាលារាជធានីភ្នំពេញ ស្នងការនគរបាលរាជធានីភ្នំពេញ មេបញ្ជាការកងរាជអាវុធហត្ថរាជធានីភ្នំពេញ អភិបាល នៃគណៈអភិបាលខណ្ឌទាំង១៤ ប្រធានមន្ទីរ-អង្គភាពជំនាញជុំវិញរដ្ឋបាលរាជធានីភ្នំពេញ វិស័យឯកជន គណៈគ្រប់គ្រងផ្សារ ម្ចាស់ដេប៉ូ ម្ចាស់អាជីវកម្មដ្ឋានផ្នែកអាហារ-ភេសជ្ជៈគ្រប់ប្រភេទ អាជីវករ បងប្អូនប្រជាពលរដ្ឋ និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ត្រូវចូលរួមអនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាព និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់៕

ថ្ងៃ អាទិត្យ ១៤កើតខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែមេសា ឆ្នាំ២០២១

**អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ**

**ឃួង ស្រេង**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសុខាភិបាល
- គ្រប់ក្រសួង-ស្ថាប័ន
  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ
- បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ
- រដ្ឋបាលខណ្ឌទាំង១៤
- គ្រប់មន្ទីរ-អង្គភាពជំនាញជុំវិញរដ្ឋបាលរាជធានីភ្នំពេញ
  "ដើម្បីមុខការ"
- គ្រប់ប្រព័ន្ធឃោសនា
  "ដើម្បីផ្សព្វផ្សាយ"
- ឯកសារ-កាលប្បវត្តិ

៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ : (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤

រាជធានីភ្នំពេញ

- អភិបាល រាជធានី
- ទិដ្ឋភាពទូទៅ
- ប្រវត្តិ
- រតនភណ្ឌនៃភ្នំពេញ
- សេវាដឹកជញ្ជូនសាធារណៈរថយន្តក្រុង
- ចំងាយពីភ្នំពេញទៅ បណ្តាខេត្ត-ក្រុង

សេវាសាធារណៈ

- វិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- វិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- វិស័យពាណិជ្ជកម្ម
- វិស័យរ៉ែ និងថាមពល
- វិស័យឧស្សាហកម្ម និងសិប្បកម្ម
- វិស័យបរិស្ថាន
- វិស័យព័ត៌មាន
- វិស័យវប្បធម៌ និងវិចិត្រសិល្បៈ
- វិស័យទេសចរណ៍
- វិស័យសាធារណការ និងដឹកជញ្ជូន
- វិស័យសុខាភិបាល
- ការងារនីត្យានុកូលកម្ម
- ការងាររដ្ឋបាល
- ការងារវិនិយោគ

ពាណិជ្ជកម្ម

- អត្ថប្រយោជន៍

- ែផនទី

សាលារាជធានីភ្នំពេញ © 2021 - ទំនាក់ទំនងយើង - Terms & Conditions